# ២-សេចក្តីសម្រេចស្តីពីការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ២០១ សសរ កសក

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែមិនា ឆ្នាំ ២០១៦

# សេចក្តីសម្រេច
## ស្តីពី
## ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈ
## របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកសិកម្មក្រសាស្ត្រនិងកែលម្អដីកសិកម្មទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ប្រកាសរួមលេខ១០១៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ប្រកាសរួមលេខ១០១៤ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សារាចរណែនាំលេខ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីគោលការណ៍ និងនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈ
- យោងតាមកំណត់ហេតុអង្គប្រជុំថ្នាក់ដឹកនាំក្រសួង និងអង្គភាពប្រមូលចំណូលក្រោមឱវាទក្រសួងចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦

## សម្រេច

ប្រការ១: អង្គភាពថ្នាក់កណ្តាល និងមន្ទីរកសិកម្មរាជធានី ខេត្ត នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានភារកិច្ចប្រមូលចំណូលពីកម្រៃសេវាសាធារៈទៅតាមប្រភេទនីមួយៗ ដែលបានកំណត់តម្លៃក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមលេខ១០១៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ត្រូវទទួលប្រាក់រង្វាន់លើកទឹកចិត្ត តាមអត្រាដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធ នៃប្រកាសរួមលេខ១០១៤ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២។

ប្រការ២: ប្រាក់រង្វាន់លើកទឹកចិត្ត ដែលត្រូវឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀតក្នុងការពង្រឹងយន្តការប្រមូលចំណូល ត្រូវបានអនុវត្តតាមសារាចរណែនាំលេខ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានអនុញ្ញាតឲ្យកាត់យកពីប្រាក់ចំណូលប្រមូលបានដោយផ្ទាល់ ហើយចាត់ទុកថាជាប្រាក់បុរេប្រទានដែលបានបើកផ្តល់ ដោយថវិកាជាតិទាំងប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទាំងប្រាក់រង្វាន់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ប្រការ៣: ក. ថ្នាក់កណ្តាល

ប្រាក់រង្វាន់លើកទឹកចិត្តទាំងអស់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបែងចែកតាមអត្រាកំណត់ដូចខាងក្រោម ៖

- នាយកដ្ឋាននីតិកម្មកសិកម្ម ផ្តល់ជូនក្រសួងចំនួន ៣០% និង៧០% សម្រាប់បែងចែកផ្ទៃក្នុងនាយកដ្ឋាននីតិកម្មកសិកម្ម (សេចក្តីសម្រេចរបស់នាយកដ្ឋាននីតិកម្មកសិកម្ម)
- អគ្គនាយកដ្ឋានកសិកម្ម ផ្តល់ជូនក្រសួងចំនួន ២០% និង៨០% សម្រាប់បែងចែកផ្ទៃក្នុងអគ្គនាយកដ្ឋានកសិកម្ម (សេចក្តីសម្រេចរបស់អគ្គនាយកដ្ឋានកសិកម្ម)
- នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ផ្តល់ជូនក្រសួងចំនួន ២០% និង៨០% សម្រាប់បែងចែកផ្ទៃក្នុងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល (សេចក្តីសម្រេចរបស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល)
- រដ្ឋបាលជលផល ផ្តល់ជូនក្រសួងចំនួន ២០% និង៨០% សម្រាប់បែងចែកផ្ទៃក្នុងរដ្ឋបាលជលផល (សេចក្តីសម្រេចរបស់រដ្ឋបាលជលផល)
- សមត្ថកិច្ចសាយតេសកម្ពុជា ផ្តល់ជូនក្រសួងចំនួន ១០% និង៩០% សម្រាប់បែងចែកក្នុងសមត្ថកិច្ចសាយតេសកម្ពុជា
- រដ្ឋបាលព្រៃឈើ ផ្តល់ជូនក្រសួងចំនួន ២០% និង៨០% សម្រាប់បែងចែកផ្ទៃក្នុងរដ្ឋបាលព្រៃឈើ (សេចក្តីសម្រេចរបស់រដ្ឋបាលព្រៃឈើ)

ខ. ថ្នាក់រាជធានី ខេត្ត

ប្រាក់រង្វាន់លើកទឹកចិត្តទាំងអស់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបែងចែកតាមអត្រាកំណត់ដូចខាងក្រោម ៖

- អង្គភាពអនុវត្តផ្ទាល់ និងមន្ត្រីជំនាញ (សេចក្តីសម្រេចរបស់ប្រធានមន្ទីរ) ៧៥%
- ថ្នាក់ដឹកនាំស្រុក (ពាក់ព័ន្ធការប្រមូលចំណូល) ៥%
- ថ្នាក់ដឹកនាំខេត្ត (ពាក់ព័ន្ធការប្រមូលចំណូល) ៥%

- មន្ទីរកសិកម្មរាជធានី ខេត្ត ឬខ័ណ្ឌរដ្ឋបាល ៥%
- អគ្គនាយកដ្ឋាន ឬនាយកដ្ឋានគ្រប់គ្រង (ពាក់ព័ន្ធការប្រមូលចំណូល) ៥%
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៥%

ប្រាក់រង្វាន់ដែលទទួលបានពីអង្គភាពខាងលើ ត្រូវបានយកមកបែងចែកដូចខាងក្រោម៖

- ថ្នាក់ដឹកនាំក្រសួង (ចាប់ពីអគ្គលេខាធិការរងឡើង) ៤០%
- មន្ត្រី១០នាយកដ្ឋានមិនមានចំណូលនៅក្រោមទីស្តីការក្រសួង ៤៥%
- រដ្ឋទេយ្យករចំណូល-រដ្ឋទេយ្យករចំណូលរង ១៥%

ប្រការ៤: អគ្គនាយកដ្ឋាន នាយកដ្ឋាន មន្ទីរកសិកម្មរាជធានី ខេត្តនីមួយៗ ត្រូវធ្វើការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តជូនមន្ត្រីរាជការក្រោមឱវាទរបស់ខ្លួន ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។ ទន្ទឹមនេះ ត្រូវយកចិត្តទុកដាក់ពង្រឹងយន្តការប្រមូលចំណូល និងលើកកម្ពស់គុណភាព ប្រសិទ្ធភាពនៃការបម្រើសេវាសាធារណៈប្រកបដោយការទទួលខុសត្រូវ និងមានតម្លាភាពក្នុងការប្រមូលចំណូល។

ប្រការ៥: រដ្ឋទេយ្យករចំណូល ឬរដ្ឋទេយ្យករចំណូលរងរបស់អគ្គនាយកដ្ឋាន នាយកដ្ឋាន មន្ទីរកសិកម្មរាជធានី ខេត្ត នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបើកផ្តល់ចំណែកប្រាក់រង្វាន់លើកទឹកចិត្តរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជូននាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី ខេត្ត នៅក្នុងសប្តាហ៍ទី៤ នៃខែនីមួយៗ។

ប្រការ៦: ត្រូវបាននិរាករណ៍សេចក្តីសម្រេចលេខ៥៦១ សសរ.កសក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣

ប្រការ៧: អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ៚

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

បណ្ឌិត អ៊ុក រ៉ាប៊ុន

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អាជ្ញាធរសវនកម្មជាតិ
- សាលារាជធានី ខេត្ត
  " ដើម្បីជូនជ្រាប "
- ដូចក្នុងប្រការ៧
  " ដើម្បីអនុវត្ត "
- ឯកសារ កាលប្បវត្តិ